**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..០០៤......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦

# សារាចរណែនាំ

## ស្តីពី

## ការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី

ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងនិងការត្រួតពិនិត្យតាមដានការអនុវត្តចំណាយថវិកាតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព, គណនេយ្យភាព, ការសន្សំសំចៃ និងឆ្លើយតបតាមតម្រូវការទាន់ពេលវេលាទៅតាមកម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវនីតិវិធីស្តីពីការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ដូចតទៅ÷

**១. ការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ច**

ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវរៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយផ្អែកតាមឥណទានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវអនុលោមតាមប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវរៀបចំតាមនីតិវិធី ដូចខាងក្រោម÷

- <u>សម្រាប់ថ្នាក់កណ្តាល</u>÷ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច គឺជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬ ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ
- <u>សម្រាប់ថ្នាក់មូលដ្ឋាន</u>÷ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច គឺជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន ដែលត្រូវចុះហត្ថលេខារួមគ្នាដោយប្រធានមន្ទីរជំនាញរាជធានី ខេត្ត ឬ ប្រធានអង្គភាពថវិកា នៃក្រសួង ស្ថាប័នថវិកាកម្មវិធី ដែលជាអាណាប័កផ្ទេរសិទ្ធិ និងប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត
- ក្នុងករណីមានតម្រូវការចាំបាច់ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច អាចអនុញ្ញាតឱ្យធ្វើការកែសម្រួលដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ជាពិសេសគឺត្រូវរក្សាទុកឥណទានសម្រាប់ទូទាត់ចំណាយតាមរដ្ឋទេយ្យបុរេប្រទានដែលបានអនុវត្តរួច។

គំរូតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១.១ និងទី១.២នៃសារាចរណែនាំនេះ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

២. ការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី

ក្រសួង ស្ថាប័នថវិកាកម្មវិធីត្រូវរៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី ដោយយកមូលដ្ឋានតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច មករាយលម្អិតតាមកម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព។ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី ត្រូវរៀបចំតាមនីតិវិធី ដូចខាងក្រោម÷

- <u>សម្រាប់ថ្នាក់កណ្តាល</u>÷ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី ត្រូវចុះហត្ថលេខាដោយអាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ នៃក្រសួង ស្ថាប័នថវិកាកម្មវិធី ហើយត្រូវចម្លងជូនអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ
- <u>សម្រាប់ថ្នាក់មូលដ្ឋាន</u>÷ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី ត្រូវចុះហត្ថលេខាដោយប្រធានមន្ទីរជំនាញរាជធានី ខេត្ត ឬ ប្រធានអង្គភាពថវិកានៃក្រសួង ស្ថាប័នថវិកាកម្មវិធី ដែលជាអាណាប័កផ្ទេរសិទ្ធិ ហើយត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត
- ក្នុងករណីមានតម្រូវការចាំបាច់ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី អាចអនុញ្ញាតឱ្យធ្វើការកែសម្រួល ដោយអនុលោមតាមចំណុចទី III. *"ការរៀបចំសៀវភៅថវិកាកម្មវិធី ការបែងចែកថវិកាកម្មវិធីតាមអង្គភាពថវិកា និងការធ្វើចលនាឥណទានថវិកាកម្មវិធី"* នៃគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ បន្ទាប់ពីបានកែសម្រួលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីរួច សម្រាប់ថ្នាក់កណ្តាល ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវចម្លងជូនអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការធ្វើនិយ័តកម្ម និងសម្រាប់ថ្នាក់មូលដ្ឋាន មន្ទីរជំនាញរាជធានី ខេត្ត ឬ អង្គភាពថវិកានៃក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវចម្លងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការធ្វើនិយ័តកម្ម។

គំរូតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធី ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី២.១ និងទី២.២ នៃសារាចរណែនាំនេះ។

គ្រប់ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវសហការអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>**ចម្លងជូន÷**</u>

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នថវិកាកម្មវិធី "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

### គំរូតារាងឧបសម្ព័ន្ធទី១.១

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមសារាចរណែនាំលេខ......ចុះថ្ងៃទី...............ស្តីពីការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី របស់ក្រសួង ស្ថាប័នថវិកាកម្មវិធី)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

### តារាងឧបសម្ព័ន្ធរង្វាន់ទេយ្យបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ.....

### របស់ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រង្វាន់ទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រង្វាន់ទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | **សរុបរួម** | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស | | | | | | (អាច ១០០%) |
| | ..... | ..... | | | | | | | |
| | 6110 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | |
| | | ..... | | | | | | | |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | | | | | | (អាច ១០០%) |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | | | | | | |
| | | 61122 | សោហ៊ុយបេសកកម្ម | | | | | | (អាច ១០០%) |
| | | 61123 | សោហ៊ុយស្នាក់នៅ | | | | | | |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | | | |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | | | | | | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | | | | | | (អាច ១០០%) |
| | | 61132 | សោហ៊ុយបេសកកម្ម | | | | | | |
| | | 61133 | សោហ៊ុយស្នាក់នៅ | | | | | | |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | | | | | | |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស...) | | | | | | |
| | ..... | ..... | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា

បានឃើញនិងឯកភាព
ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋមន្ត្រី

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក/ប្រធាននាយកដ្ឋាន...

ថ្ងៃទី.....ខែ.......ឆ្នាំ....
រង្វាន់ទេយ្យករបុរេប្រទាន

បានឃើញនិងឯកភាព
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័ក

គំរូតារាងឧបសម្ព័ន្ធទី១.២

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមសារាចរណែនាំលេខ...... ចុះថ្ងៃទី............... ស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីរបស់មន្ទីរជំនាញរាជធានី ខេត្ត)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

មន្ទីរ....

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ.....

## របស់មន្ទីរ.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | **សរុបរួម** | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស | | | | | | *(អាច ១០០%)* |
| | ..... | ..... | | | | | | | |
| | 6110 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | |
| | | ..... | | | | | | | |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | | | | | | *(អាច ១០០%)* |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | | | | | | |
| | | 61122 | សោហ៊ុយបេសកកម្ម | | | | | | *(អាច ១០០%)* |
| | | 61123 | សោហ៊ុយស្នាក់នៅ | | | | | | |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | | | |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | | | | | | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | | | | | | *(អាច ១០០%)* |
| | | 61132 | សោហ៊ុយបេសកកម្ម | | | | | | |
| | | 61133 | សោហ៊ុយស្នាក់នៅ | | | | | | |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | | | | | | |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស...) | | | | | | |
| | ..... | ..... | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរ......រាជធានី ខេត្ត......

ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

គំរូតារាងឧបសម្ព័ន្ធទី២.១

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមសារាចរណែនាំលេខ......ចុះថ្ងៃទី...............ស្តីពីការបង្កើតវិជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័នថវិកាកម្មវិធី)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

## តារាងឧបសម្ព័ន្ធវិជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីឆ្នាំ.....

## របស់ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធីទី.... | | | | | | អនុកម្មវិធី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានវិជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្គិលវិជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានវិជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្គិលវិជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានវិជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្គិលវិជ្ជទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | សរុបរួម | | | | | | | | | | | | | | | | | | |
| 60 | | | ការទិញ | | | | | | | | | | | | | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | | | | | | | | | | | | | |
| | | 60011 | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 61 | | | សេវាកម្ម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | 6110 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | | | | | | | | | | | | | |
| | | ..... | | | | | | | | | | | | | | | | | | | |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | | | | | | | | | | | | | | | | | | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | | | | | | | | | | | | | |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | | | | | | | | | | | | | | | | | | |
| | | 61122 | សោហ៊ុយបេសកកម្ម | | | | | | | | | | | | | | | | | | |
| | | 61123 | សោហ៊ុយស្នាក់នៅ | | | | | | | | | | | | | | | | | | |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | | | | | | | | | | | | | | | |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | | | | | | | | | | | | | | | | | | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | | | | | | | | | | | | | | | | | | |
| | | 61132 | សោហ៊ុយបេសកកម្ម | | | | | | | | | | | | | | | | | | |
| | | 61133 | សោហ៊ុយស្នាក់នៅ | | | | | | | | | | | | | | | | | | |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | | | | | | | | | | | | | | | | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធីទី.... | | | | | | អនុកម្មវិធីទី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស...) | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័ក

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក/ប្រធាននាយកដ្ឋាន...

ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

គំរូតារាងឧបសម្ព័ន្ធទី២.២

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមសារាចរណែនាំលេខ......ចុះថ្ងៃទី................ស្ដីពីការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីរបស់មន្ទីរជំនាញរាជធានី ខេត្ត)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័នថវិកាកម្មវិធី.....

មន្ទីរ...

**តារាងឧបសម្ព័ន្ធរង្វាន់ទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីឆ្នាំ.....**

**របស់មន្ទីរ.....**

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធី.... | | | | | | អនុកម្មវិធី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរង្វាន់ទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរង្វាន់ទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរង្វាន់ទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរង្វាន់ទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរង្វាន់ទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរង្វាន់ទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | **សរុបរួម** | | | | | | | | | | | | | | | | | | |
| 60 | | | ការទិញ | | | | | | | | | | | | | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | | | | | | | | | | | | | |
| | | 60011 | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 61 | | | សេវាកម្ម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | 6104 | | សោហ៊ុយបណ្ដុះបណ្ដាលបុគ្គលិកក្នុងនិងក្រៅប្រទេស | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | 6110 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | | | | | | | | | | | | | |
| | | ..... | | | | | | | | | | | | | | | | | | | |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | | | | | | | | | | | | | | | | | | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | | | | | | | | | | | | | |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | | | | | | | | | | | | | | | | | | |
| | | 61122 | សោហ៊ុយបេសកកម្ម | | | | | | | | | | | | | | | | | | |
| | | 61123 | សោហ៊ុយស្នាក់នៅ | | | | | | | | | | | | | | | | | | |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | | | | | | | | | | | | | | | |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | | | | | | | | | | | | | | | | | | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | | | | | | | | | | | | | | | | | | |
| | | 61132 | សោហ៊ុយបេសកកម្ម | | | | | | | | | | | | | | | | | | |
| | | 61133 | សោហ៊ុយស្នាក់នៅ | | | | | | | | | | | | | | | | | | |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | | | | | | | | | | | | | | | | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធីទី.... | | | | | | អនុកម្មវិធី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស...) | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័កផ្ទេរសិទ្ធិ/ប្រធានមន្ទីរ...

ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន